ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការសកម្មភាពជាតិ
# ស្ដីពី
# ការអភិវឌ្ឍយុវជនកម្ពុជា
# ២០២២-២០២៦

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន**

# ផែនការសកម្មភាពជាតិ
# ស្តីពី
# ការអភិវឌ្ឍយុវជនកម្ពុជា
# ២០២២-២០២៦

បានទទួលការឯកភាពដ៏ខ្ពង់ខ្ពស់ពី
សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
និងជាប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន
នាថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២

# បុព្វកថា

រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកការអភិវឌ្ឍយុវជនគឺជាអាទិភាពចម្បង និងជាមូលដ្ឋានដ៏រឹងមាំមួយក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិ។ ដើម្បីបង្ហាញពីការប្តេជ្ញាចិត្តក្នុងការអភិវឌ្ឍយុវជន រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវ «**គោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា**» ដែលមានចក្ខុវិស័យវែងឆ្ងាយក្នុងការប្រមូលផ្តុំកម្លាំងពីគ្រប់មជ្ឈដ្ឋានក្នុងសង្គមជាតិ សំដៅរួមចំណែកអភិវឌ្ឍយុវជនឱ្យមានសម្បទាគ្រប់ជ្រុងជ្រោយ ជាពិសេសសម្បទាសតវត្សរ៍ទី២១ ឆ្លើយតបទៅនឹងការវិវឌ្ឍជាសាកលនៃបដិវត្តន៍ឧស្សាហកម្ម ៤.០ នៃយុគសម័យឌីជីថល។ គោលនយោបាយនេះ ក៏បានផ្តល់ឱកាសឱ្យយុវជនអភិវឌ្ឍសក្តានុពលរបស់ខ្លួន ទាំងផ្នែក រាងកាយ បញ្ញា ស្មារតី សីលធម៌ តម្លៃ និងបំណិន ដើម្បីក្លាយខ្លួនជាមូលធនមនុស្សក្នុងសង្គមជាតិ និងជាពលរដ្ឋសាកល។ ជាងនេះទៅទៀត យុវជនក៏ទទួលបានការអប់រំឱ្យចេះរួមរស់ជាមួយគ្នា ដោយសន្តិភាពនិងសុខដុម គោរពភាពចម្រុះទាំងជំនឿសាសនា និងវប្បធម៌ ព្រមទាំងមានស្មារតីស្នេហាជាតិ ស្នេហាមនុស្សជាតិ ប្រកបដោយជំនឿជាក់លើខ្លួនឯង សេចក្តីថ្លៃថ្នូរ និងភាពជាអ្នកដឹកនាំ។

ដើម្បីសម្រេចបាននូវគោលបំណងខាងលើ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន បានរៀបចំ «**ផែនការសកម្មភាពជាតិ ស្តីពីការអភិវឌ្ឍយុវជនកម្ពុជាឆ្នាំ២០២២-២០២៦**» ដែលផ្តោតលើយុទ្ធសាស្ត្រចំនួន ១២ និងអាទិភាពសំខាន់ៗចំនួន ៥ រួមមាន៖ ១) ការអប់រំ ២) សុខភាពនិងសុខុមាលភាព ៣) ការងារនិងឱកាស ៤) ការចូលរួមនិងសមត្ថភាពស្ថាប័នក្នុងការសម្របសម្រួល និង៥) ការពិនិត្យតាមដាន និងវាយតម្លៃ។ ផែនការសកម្មភាពជាតិ បង្ហាញពីយុទ្ធសាស្ត្រ សកម្មភាព សូចនាករ ចំណុចដៅ និងការពិនិត្យតាមដាននិងវាយតម្លៃ។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមសំដែងនូវការកោតសរសើរ ចំពោះក្រសួង ស្ថាប័នរដ្ឋ វិស័យឯកជន ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល ភ្នាក់ងារអង្គការសហប្រជាជាតិ និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ដែលបានចូលរួមយ៉ាងសកម្ម ក្នុងការរៀបចំផែនការសកម្មភាពជាតិ ស្តីពីការអភិវឌ្ឍយុវជនកម្ពុជានេះ សម្រាប់ជាត្រីវិស័យក្នុងការអភិវឌ្ឍយុវជន។

រាជរដ្ឋាភិបាលកម្ពុជាសង្ឃឹមយ៉ាងមុតមាំថា ក្រសួង ស្ថាប័ន ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ វិស័យឯកជន ដៃគូអភិវឌ្ឍ ភាគីពាក់ព័ន្ធទាំងអស់ សហគមន៍ គ្រួសារ និងជាពិសេសយុវជន ចូលរួមផ្សព្វផ្សាយ គាំទ្រ និងអនុវត្តផែនការសកម្មភាពជាតិនេះ ឱ្យទទួលបានជោគជ័យ ដែលជាមូលដ្ឋានសម្រាប់អភិវឌ្ឍសង្គមជាតិប្រកបដោយចីរភាព។

ថ្ងៃសុក្រ ៣រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២

**ប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

## មាតិកា


**១. សារបាន** ........................................................................................ ១

១.១. គោលនយោបាយ ........................................................................................ ១

១.២. ស្ថានភាពនៃការអភិវឌ្ឍយុវជន ........................................................................................ ២

១.៣. បញ្ហាអាទិភាព ........................................................................................ ៥

**២. យុទ្ធសាស្ត្រ** ........................................................................................ ៧

២.១. យន្តការសម្របសម្រួល ........................................................................................ ៧

២.២. ក្របខណ្ឌយុទ្ធសាស្ត្រ ........................................................................................ ៧

**៣. ផែនការសកម្មភាព** ........................................................................................ ៩

៣.១. បរិយាយសង្ខេបអំពីវិសាលភាពនៃផែនការ ........................................................................................ ៩

៣.២. តារាងអនុវត្តការងារ ........................................................................................ ៩

**៤. កាលវិភាគរៀបចំសេចក្តីព្រាងច្បាប់ លិខិតបទដ្ឋានគតិយុត្ត** ........................................................................................ ២៩

**៥. គម្រោងចំណាយ** ........................................................................................ ២៩

**៦. ការពិនិត្យតាមដាន និងវាយតម្លៃ** ........................................................................................ ៣០

**៧. សេចក្តីសន្និដ្ឋាន** ........................................................................................ ៣១

# ១. សារបាន

## ១.១. គោលនយោបាយ

គោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា បានទទួលការឯកភាពជាផ្លូវការពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១។ គោលនយោបាយនេះ ត្រូវបានរៀបចំឡើងក្រោមការដឹកនាំ និងសម្របសម្រួលដោយក្រសួងអប់រំ យុវជន និងកីឡា និងមានកិច្ចសហការពេញលេញពីក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍ និងអង្គការសង្គមស៊ីវិលនានា ដែលកំពុងបំពេញការងារពាក់ព័ន្ធនឹងយុវជន។ យុទ្ធសាស្ត្រនៅក្នុងគោលនយោបាយត្រូវបានប្រែក្លាយទៅជាផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា ហើយការអនុវត្តដ៏មានប្រសិទ្ធភាពអាចសម្រេចទៅបាន លុះត្រាតែភាគីពាក់ព័ន្ធក្នុងសង្គមទទួលស្គាល់ពីសារៈសំខាន់នៃការអភិវឌ្ឍយុវជន និងតួនាទីដ៏សំខាន់ដែលយុវជនត្រូវបំពេញនៅក្នុងសង្គម។

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន (ក.ជ.យ.) មានតួនាទី និងភារកិច្ចក្នុងការអភិវឌ្ឍគោលនយោបាយ និងគោលការណ៍ណែនាំក្នុងការសម្របសម្រួល ត្រួតពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយ និងផែនការសកម្មភាព ដើម្បីធានាប្រសិទ្ធភាពនៃការអភិវឌ្ឍយុវជន។ អគ្គលេខាធិការដ្ឋាន ក.ជ.យ. មានតួនាទីគាំទ្រ ក.ជ.យ. ក្នុងការបំពេញតួនាទីខាងលើនេះ។

ក្នុងឆ្នាំ២០១៦ ក.ជ.យ. បានអនុម័តផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជាឆ្នាំ២០១៦-២០១៨ ដើម្បីជាក្របខណ្ឌគាំទ្រដល់ការអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជន។ ការអនុវត្តផែនការសកម្មភាពជាតិនេះត្រូវបានបញ្ចប់ជាស្ថាពរក្នុងឆ្នាំ២០១៨ និងត្រូវបានវាយតម្លៃនៅដើមឆ្នាំ២០១៩។ ការវាយតម្លៃបានបង្ហាញអំពីវឌ្ឍនភាព ជាច្រើន ប៉ុន្តែក៏នៅមានបញ្ហាប្រឈមចម្បងៗ និងកិច្ចការមួយចំនួនទៀត ដែលត្រូវអនុវត្តបន្ត។

ឆ្លងតាមបទពិសោធន៍ក្នុងការអនុវត្តផែនការសកម្មភាពជាតិលើកទី១ អគ្គលេខាធិការដ្ឋាន ក.ជ.យ. ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍ បានសម្របសម្រួល និងប្រឹក្សាជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គភាពថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល និងជាពិសេសជាមួយយុវជន (រួមទាំងយុវជនងាយរងគ្រោះ និងយុវជនមកពីសហគមន៍ជនជាតិដើមភាគតិច) ដើម្បីប្រមូលធាតុចូលសម្រាប់ការអភិវឌ្ឍផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជាលើកទី២ សម្រាប់អនុវត្តឆ្នាំ២០២២-២០២៦។ ដើម្បីធានាប្រសិទ្ធភាពក្នុងការសម្របសម្រួល និងការពិនិត្យតាមដាន និងវាយតម្លៃលើផែនការសកម្មភាពជាតិនេះ អគ្គលេខាធិការដ្ឋាន ក.ជ.យ. ត្រូវរៀបចំផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពរបស់ខ្លួន ដើម្បីសម្រេចបាននូវសូចនាករ និងចំណុចដៅ ដែលបានកំណត់នៅក្នុងផែនការសកម្មភាពជាតិ ស្តីពីការអភិវឌ្ឍយុវជនកម្ពុជាឆ្នាំ២០២២-២០២៦។

ផែនការសកម្មភាពជាតិ ស្តីពីការអភិវឌ្ឍយុវជនកម្ពុជាឆ្នាំ២០២២-២០២៦ ត្រូវបានរៀបចំឡើងដើម្បីកំណត់អំពីៈ

- ស្ថានភាព និងបញ្ហាជាអាទិភាពសំខាន់ៗ ដើម្បីលើកយកមកដោះស្រាយឱ្យឆ្លើយតបនឹងតម្រូវការរបស់យុវជន ដែលស្របជាមួយគោលនយោបាយ របស់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ និងគោលដៅអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ២០៣០ របស់កម្ពុជា
- សកម្មភាពជាក់លាក់ដែលត្រូវអនុវត្តដោយភាគីពាក់ព័ន្ធ ដោយអនុលោមតាមយុទ្ធសាស្ត្រទាំង ១២ នៃគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា (២០១១) និងដែលត្រូវពិនិត្យតាមដានក្នុងក្របខណ្ឌ នៃផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជាលើកទី២
- សូចនាករ និងចំណុចដៅជាក់លាក់ ដែលនឹងប្រើប្រាស់សម្រាប់វាយតម្លៃលើវឌ្ឍនភាពនៃការអនុវត្តសកម្មភាព
- យន្តការ និងដំណើរការសម្រាប់ការងារសម្របសម្រួល ពិនិត្យតាមដាន និងចែករំលែកអំពីវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពជាតិទៅកាន់ភាគីពាក់ព័ន្ធសំខាន់ៗ និងយុវជនផ្ទាល់។

## ១.២. ស្ថានភាពនៃការអភិវឌ្ឍយុវជន

ប្រទេសកម្ពុជាមានប្រជាជនជាយុវជន (អាយុចន្លោះពី ១៥ ទៅ ៣០ឆ្នាំ) ចំនួនប្រមាណ ៣០,៥% នៃប្រជាជនសរុប។ យោងតាមសន្ទស្សន៍ស្តីពីការអភិវឌ្ឍយុវជនកម្ពុជា និងការវាយតម្លៃលើកចុងក្រោយនៃផែនការសកម្មភាពជាតិ ស្តីពីការអភិវឌ្ឍយុវជនកម្ពុជាឆ្នាំ២០១៦-២០១៨ ការអភិវឌ្ឍយុវជនស្ថិតនៅក្នុងកន្សោមអាទិភាពសំខាន់ៗចំនួន ៤៖ ១) ការអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ២) សុខភាពនិងសុខុមាលភាព ៣) ការងារនិងឱកាស និង៤) ការចូលរួមរបស់យុវជន។ ការស្រាវជ្រាវ និងទិន្នន័យដែលមានស្រាប់បានបង្ហាញទាំងវឌ្ឍនភាព និងបញ្ហាប្រឈម ដែលមានក្នុងវិស័យនីមួយៗ។

**ការអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ៖** ការអប់រំចំណេះដឹងទូទៅនៅកម្ពុជារួមមាន ការសិក្សាកម្រិតបឋមសិក្សាចំនួន ៦ឆ្នាំ មធ្យមសិក្សាបឋមភូមិចំនួន ៣ឆ្នាំ និងមធ្យមសិក្សាទុតិយភូមិចំនួន ៣ឆ្នាំ។ ការចុះឈ្មោះចូលរៀននៅកម្រិតបឋមសិក្សាទាំងសាលារដ្ឋ និងឯកជន មានការរីកចម្រើនគួរឱ្យកត់សម្គាល់ ដោយអត្រាពិតនៃការចុះឈ្មោះចូលរៀនក្នុងឆ្នាំសិក្សា ២០១៩-២០២០ កើនរហូតដល់ ៩៧,៣០% និងអត្រាបញ្ចប់ការសិក្សាកើនឡើងដល់ ៨៨,២០%។ ទោះយ៉ាងណា ការសិក្សារបស់សិស្ស ជាពិសេសនៅតាមតំបន់ជនបទនៅត្រូវការការយកចិត្តទុកដាក់បន្ថែម។ ការចូលរៀននៅកម្រិតមធ្យមសិក្សាបឋមភូមិ មានការរីកចម្រើនគួរឱ្យកត់សម្គាល់។ អត្រារួមនៃការចុះឈ្មោះចូលរៀននៅមធ្យមសិក្សាបឋមភូមិ ក្នុងឆ្នាំសិក្សា ២០១៩-២០២០ កើនឡើងក្នុងរយៈពេល ៥ឆ្នាំចុងក្រោយ ដែលបានកើនដល់ ៥៩,៩០%។ អត្រារួមនៃការចុះឈ្មោះចូលរៀននៅមធ្យមសិក្សាទុតិយភូមិបានកើនឡើងដល់ ៣០,៩០% នៅក្នុងឆ្នាំសិក្សា ២០១៩-២០២០។

អត្រាចុះឈ្មោះចូលរៀនរបស់និស្សិតនៅថ្នាក់ឧត្តមសិក្សាមានការប្រសើរឡើងជាលំដាប់។ ក្រសួងអប់រំ យុវជន និងកីឡាបានលើកកម្ពស់ និងបង្កើនចំនួននិស្សិតឱ្យទទួលបានការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈ និងគណិតវិទ្យា (STEAM) នៅឧត្តមសិក្សាតាមរយៈការជំរុញនិងការគាំទ្រក្នុងការបង្កើតកម្មវិធីបណ្តុះបណ្តាលថ្មី និងគ្រឹះស្ថានឧត្តមសិក្សាថ្មីៗ ដែលផ្តោតទៅលើស្ទីម (STEAM)។ ជាមួយនឹងនិន្នាការពិភពលោក និងតម្រូវការជ... ...ប់រជីវិល ដែលជា

មូលដ្ឋានគ្រឹះក្នុងការកសាងសេដ្ឋកិច្ចឌីជីថល ក្រសួងអប់រំ យុវជន និងកីឡាបាននឹងកំពុងធ្វើការអភិវឌ្ឍក្របខណ្ឌសមត្ថភាពនៃការអប់រំឌីជីថល ដែលនឹងផ្ដល់នូវយុទ្ធសាស្ត្រ និងគោលការណ៍ណែនាំសម្រាប់ការអនុវត្ត ដើម្បីរួមបញ្ចូលការអប់រំឌីជីថលនៅតាមសាលារៀននៅគ្រប់កម្រិតសិក្សា។ យុវជនកម្ពុជាចាំបាច់ត្រូវមានជំនាញបច្ចេកវិទ្យាដែលរួមមាន រ៉ូបូត បញ្ញាសិប្បនិម្មិត ទិន្នន័យធំ និងការគិតបែបឌីជីថល «ការគ្រប់គ្រងព័ត៌មានតាមអ៊ីនធឺណិត ការសហការតាមអ៊ីនធឺណិត សុវត្ថិភាពព័ត៌មានវិទ្យា ការវិភាគនិងការសរសេរកូដ ការស្វែងរកព័ត៌មានតាមអ៊ីនធឺណិត ការប្រើប្រាស់អ៊ីម៉ែលប្រកបដោយវិជ្ជាជីវៈ ការរចនាគេហទំព័រ និងប្លុក»។

ការពង្រីកលទ្ធភាពកាន់តែងាយស្រួលសម្រាប់យុវជនគ្រប់រូប ក្នុងការទទួលបានការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈប្រកបដោយគុណភាព សមធម៌និងបរិយាប័ន្ន សំដៅជានាឱ្យ «យុវជនម្នាក់មានជំនាញមួយយ៉ាងតិចប្រចាំជីវិត» ឆ្លើយតបបានទៅនឹងតម្រូវការទីផ្សារការងារ និងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ត្រូវបានផ្ដល់អាទិភាពខ្ពស់នៅក្នុងក្របខណ្ឌគោលនយោបាយជាបន្តបន្ទាប់របស់រាជរដ្ឋាភិបាល។ ការកែទម្រង់ជាប្រព័ន្ធ និងការវិនិយោគយ៉ាងច្រើនកន្លងមកលើហេដ្ឋារចនាសម្ព័ន្ធទាំងផ្នែករឹង ដូចជាអគារសិក្សា រោងជាង បន្ទប់ពិសោធន៍ អន្តេវាសិកដ្ឋាន និងទាំងផ្នែកទន់ រួមមាន គ្រូបច្ចេកទេស ក្របខណ្ឌគុណវុឌ្ឍិជាតិ កម្មវិធីបណ្ដុះបណ្ដាលផ្អែកលើសមត្ថភាព ប្រព័ន្ធទទួលស្គាល់សមត្ថភាពពីមុននិងបច្ចុប្បន្ន កម្មវិធីស្ពានចម្លងបន្តជំនាញ អាហារូបករណ៍ បានផ្ដល់ឱកាសដល់យុវជនអាចទទួលបានការបណ្តុះបណ្តាលរយៈពេលខ្លី រយៈពេលវែង ក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ នៅតាមគ្រឹះស្ថាន សហគ្រាស សហគមន៍ ឬចល័តនៅគ្រប់រាជធានី ខេត្ត ទូទាំងប្រទេស។ ទន្ទឹមនេះ គុណភាពបណ្ដុះបណ្ដាលត្រូវបានចាត់ទុកជាអាទិភាព តាមរយៈការដាក់ចេញប្រព័ន្ធធានាគុណភាព ការពង្រីកកម្មសិក្សា និងហាត់ការផ្ទាល់នៅកន្លែងការងារ ការជំរុញការស្រាវជ្រាវ និងនវានុវត្តន៍លើបច្ចេកវិទ្យាអនុវត្តន៍ សំដៅជានាឱ្យយុវជនដែលទទួលបានការបណ្ដុះបណ្ដាល មានចំណេះដឹង ជំនាញច្បាស់លាស់ ព្រមទាំងឥរិយាបទ និងសីលធម៌វិជ្ជាជីវៈល្អ និងភាពប្រកួតប្រជែងខ្ពស់ អាចឈានចាប់យកឱកាសការងារកាន់តែល្អ ស្របតាមការវិវត្តដ៏លឿន នៃបច្ចេកវិទ្យា និងចូលរួមចំណែកកាន់តែខ្លាំងឡើងក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គមនាពេលបច្ចុប្បន្ននិងពេលអនាគត។ ជាក់ស្តែង ក្នុងរយៈពេល ៥ឆ្នាំចុងក្រោយនេះ មានយុវជនជាង ២០ម៉ឺននាក់បានទទួលការបណ្ដុះបណ្ដាលជំនាញ។

ទោះយ៉ាងណា យុវជនក៏នៅជួបបញ្ហាប្រឈមចម្បងៗពាក់ព័ន្ធនឹងការទទួលបានជំនាញសមស្របសម្រាប់ចូលទីផ្សារការងារ និងការផ្លាស់ប្ដូរទៅចាប់យកការងារថ្មីឆ្លើយតបទៅនឹងការប្រែប្រួលរចនាសម្ព័ន្ធសេដ្ឋកិច្ច បច្ចេកវិទ្យា និងបំណងប្រាថ្នាកាន់តែខ្ពស់របស់ខ្លួន ដោយសារកត្តាសំខាន់ៗដូចជា ការបោះបង់ចោលការសិក្សា និងចូលទីផ្សារការងារដោយគ្មានជំនាញវិជ្ជាជីវៈច្បាស់លាស់ គុណភាពអប់រំបណ្ដុះបណ្ដាលមិនទាន់ឆ្លើយតបទាំងស្រុងទៅនឹងតម្រូវការ ឱកាសទទួលបានការបណ្ដុះបណ្ដាលលើកកម្ពស់ និងពង្រីកជំនាញថ្មីមិនមានពេញលេញគ្រប់ពេលនិងទីកន្លែង។

**សុខភាព និងសុខមាលភាព៖** ក្នុងមួយទសវត្សរ៍កន្លងមកនេះ ស្ថានភាពសុខភាពយុវជនមានការរីកចម្រើនគួរឱ្យកត់សម្គាល់។ អត្រាមរណភាពមាតាជាយុវជន មានការថយចុះពី ៣,៧៦% ក្នុងឆ្នាំ២០១៣ មក ២,០៧% ក្នុងឆ្នាំ២០១៥[1]។ ចំនួនអ្នកស្លាប់ដោយមេរោគអេដស៍បានធ្លាក់ចុះ ៣,៥ដង។ ប៉ុន្តែ ក្នុងពេលជាមួយគ្នានេះ គ្រោះថ្នាក់លើដងផ្លូវបានក្លាយជា

---

[1] សន្ទស្សន៍អភិវឌ្ឍន៍យុវជនកម្ពុជាឆ្នាំ២០១៨

មូលហេតុចម្បងមួយ ដែលនាំឱ្យបាត់បង់អាយុជីវិតរបស់យុវជន។ ការប្រើប្រាស់គ្រឿងស្រវឹង ក្នុងចំណោមក្មេងជំទង់ ជាពិសេសក្មេងប្រុស កំពុងតែកើនឡើង ជាចំណែកបង្កឱ្យមានគ្រោះថ្នាក់ចរាចរណ៍។ សុខភាពផ្លូវភេទ និងសុខភាពបន្តពូជ គឺជាក្តីកង្វល់ ជាពិសេសសម្រាប់ក្មេងស្រីនិងស្ត្រីវ័យជំទង់។

**ការងារ និងឱកាសៈ** ក្នុងឆ្នាំ២០១៧ អត្រាការចូលរួមកម្លាំងពលកម្មគឺខ្ពស់ ៨៤% (ប្រុស ៨៩% និងស្រី ៨០%)។ ទោះបីអត្រាគ្មានការងារធ្វើរបស់យុវជនទាបស្មើនឹង ០,៧% ហើយអត្រាយុវជនធ្វើការងារទទួលបានប្រាក់ឈ្នួលមានការកើនឡើងក៏ដោយ ក៏គុណភាពការងារនៅកម្ពុជានៅតែមានកម្រិត។

ការសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់នាពេលកន្លងមក នាំឱ្យមានការបង្កើតឱកាសការងារនិងមុខរបរថ្មីជាច្រើនសម្រាប់យុវជន ទាំងអ្នកទើបដល់អាយុចូលធ្វើការងារ ទាំងអ្នកទើបបញ្ចប់ការសិក្សា ព្រមទាំងអ្នកដែលចាកចេញពីវិស័យកសិកម្មដើម្បីទៅរកឱកាសការងារប្រសើរជាងនៅក្នុងវិស័យឧស្សាហកម្មនិងសេវាកម្ម។ ការបន្តធ្វើសមាហរណកម្មកាន់តែជ្រៅទៅក្នុងតំបន់និងសាកលលោក រួមទាំងការខិតខំពង្រីកទំនាក់ទំនងជាមួយប្រទេសនានា បានបង្កើតឱកាសការងារបន្ថែមនៅក្រៅប្រទេស ដែលផ្តល់ជម្រើសកាន់តែទូលំទូលាយសម្រាប់យុវជន។ ការខិតខំរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍស្ថាប័ន និងលើកកម្ពស់ប្រសិទ្ធភាពទីផ្សារការងារ ដូចជា ប្រព័ន្ធសេវាការងារសាធារណៈ និងព័ត៌មានទីផ្សារការងារ បានជំរុញឱ្យអត្រាចូលរួមក្នុងកម្លាំងពលកម្មមានកម្រិតខ្ពស់ និងអត្រាគ្មានការងារធ្វើមានកម្រិតទាបក្នុងចំណោមយុវជន ជាពិសេសស្ត្រី។ ទន្ទឹមនឹងការផ្លាស់ប្តូររចនាសម្ព័ន្ធទីផ្សារការងារក្នុងល្បឿនលឿនពីវិស័យកសិកម្មទៅវិស័យឧស្សាហកម្ម និងសេវាកម្ម ព្រមទាំងពីវិស័យក្រៅប្រព័ន្ធទៅវិស័យក្នុងប្រព័ន្ធ គុណភាពនិងលក្ខខណ្ឌការងារសម្រាប់យុវជនមានភាពកាន់តែប្រសើរ ដោយអត្រាយុវជនដែលធ្វើការដោយទទួលប្រាក់ឈ្នួលបានកើនឡើងជាបន្តបន្ទាប់។ លើសពីនេះ ការដាក់ចេញ និងពង្រីកជាបន្តបន្ទាប់នូវប្រព័ន្ធគាំពារនិងជំនួយសង្គម បានចូលរួមចំណែកធានាបានកាន់តែរឹងមាំនូវស្ថិរភាព និងសន្តិសុខការងារសម្រាប់យុវជន។

ទោះជាមានការរីកចម្រើនជាបន្តបន្ទាប់ ប៉ុន្តែយុវជនក៏នៅជួបនឹងបញ្ហាប្រឈមចម្បងៗមួយចំនួនក្នុងការឈានចូលទីផ្សារការងារដោយជោគជ័យបានឆាប់រហ័ស និងចាប់យកឱកាសការងារថ្មីកាន់តែប្រសើរទាំងនៅក្នុងនិងនៅក្រៅប្រទេស ក៏ដូចជាផ្លាស់ប្តូរពីការងារមួយទៅមួយទៀតទាំងក្នុងពេលដែលសេដ្ឋកិច្ចមានការរីកលូតលាស់ ទាំងក្នុងពេលជួបវិបត្តិដែលកំណើនមានការថមថយ ដូចករណីបច្ចុប្បន្ននៃការរីករាលដាលជំងឺកូវីដ-១៩ ដោយសារយុវជនមិនទាន់មានការយល់ដឹងអំពីសារៈសំខាន់នៃការរៀបចំ និងកែតម្រូវផែនការអាជីពផ្ទាល់ខ្លួនឱ្យបានត្រឹមត្រូវ និងជាប្រចាំឆ្លើយតបទៅនឹងការប្រែប្រួលចំណង់ចំណូលចិត្ត និងតម្រូវការទីផ្សារការងារ ដើម្បីធ្វើការអភិវឌ្ឍ និងលើកកម្ពស់ចំណេះដឹងជំនាញ ចំណេះធ្វើ និងបទពិសោធន៍ សំដៅត្រៀមខ្លួនចាប់យកឱកាសការងារឱ្យបានរួចស្រេចគ្រប់ពេល។ លើសពីនេះ ការផ្តល់ការគាំទ្រចាំបាច់សំខាន់ៗដូចជា សេវាការងារ ការប្រឹក្សាយោបល់អាជីពនិងការបណ្តុះបណ្តាលជំនាញ ព័ត៌មានទីផ្សារការងារបច្ចុប្បន្ន និងពេលអនាគតទាំងក្នុងនិងក្រៅប្រទេស ព្រមទាំងលទ្ធភាពក្នុងការទទួលបានការបណ្តុះបណ្តាលជំនាញឡើងវិញ និងពង្រីកជំនាញ នៅមានកម្រិតកំណត់នៅឡើយសម្រាប់យុវជន។ ជាមួយនេះ យុវជន ជាពិសេសអ្នកដែលទទួលបានការអប់រំតិច និងមានកម្រិតជំនាញទាប ប្រឈមហានិភ័យខ្ពស់ទៅនឹងការបាត់បង់ការងារក្នុងស្ថានភាពដែលសេដ្ឋកិច្ចកំពុងជួបវិបត្តិ និងការកើនឡើងនៃការជំនួសកម្លាំងពលកម្មមនុស្សដោយស្វ័យប្រវត្តិកម្មនិងរ៉ូបូត។

**ការចូលរួមរបស់យុវជន៖** យុវជនកម្ពុជាមានធន្ទៈនៅក្នុងការចូលរួម និងការចែករំលែក។ ជាមួយនឹងភាគរយខ្ពស់ក្នុងការប្រើប្រាស់អ៊ីនធឺណិត យុវជនអាចទទួលបានព័ត៌មានបន្ថែម និងបញ្ចេញការយល់ឃើញរបស់ពួកគេ។ នៅក្នុងជួររាជរដ្ឋាភិបាល ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យុវជនកាន់តែច្រើនដែលរួមទាំងស្ត្រីផង បានដើរតួនាទីយ៉ាងសកម្មទាំងនៅក្នុងមុខតំណែងបច្ចេកទេស និងតួនាទីគ្រប់គ្រងសំខាន់ៗ។

## ១.៣_ បញ្ហាអាទិភាព

អាទិភាពនៃផែនការសកម្មភាពជាតិ ស្តីពីការអភិវឌ្ឍយុវជនកម្ពុជាឆ្នាំ២០២២-២០២៦ ត្រូវបានកំណត់ឡើងដោយឈរលើការប្រឹក្សាយោបល់ និងទិន្នន័យដែលមានស្រាប់ និងមានសង្គតិភាពជាមួយគោលនយោបាយជាតិ ស្តីពីការអភិវឌ្ឍយុវជនកម្ពុជា (២០១១) និងគោលនយោបាយពាក់ព័ន្ធផ្សេងទៀត ជាពិសេសយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល។ ដូច្នេះ ផែនការសកម្មភាពជាតិ ស្តីពីការអភិវឌ្ឍយុវជនកម្ពុជាឆ្នាំ២០២២-២០២៦ ផ្តោតលើអាទិភាពសំខាន់ៗចំនួន ៥ ដូចខាងក្រោម៖

- **អាទិភាពទី១៖** សមត្ថភាពស្ថាប័នក្នុងការសម្របសម្រួល និងការពិនិត្យតាមដាន និងវាយតម្លៃ
- **អាទិភាពទី២៖** ការអប់រំ ជំនាញវិជ្ជាជីវៈ និងការអភិវឌ្ឍសមត្ថភាព
- **អាទិភាពទី៣៖** សុខភាព សុវត្ថិភាព និងសុខុមាលភាព
- **អាទិភាពទី៤៖** ការងារនិងសហគ្រិនភាព
- **អាទិភាពទី៥៖** ការចូលរួមរបស់យុវជននិងការងារស្ម័គ្រចិត្ត

ការអភិវឌ្ឍប្រកបដោយបរិយាបន្ន និងសមភាពយេនឌ័រ ត្រូវបានចាត់ទុកជាគោលដៅរួម ជាពិសេសសម្រាប់អាទិភាពទី២ ដល់អាទិភាពទី៥។ ការយកចិត្តទុកដាក់បន្ថែមនឹងត្រូវផ្តល់ជូនដល់ក្រុមយុវជនងាយរងគ្រោះរួមមាន៖ យុវជននៅជនបទដាច់ស្រយាល យុវជនក្រៅសាលា យុវជនចំណាកស្រុក យុវជនមានពិការភាព យុវជនមកពីសហគមន៍ជនជាតិដើមភាគតិច និងយុវជននៃក្រុមអ្នកស្រឡាញ់ភេទដូចគ្នា (LGBTQI)។ កិច្ចការនេះ ជាស្នូលអន្តរវិស័យដែលត្រូវយកចិត្តទុកដាក់និងឆ្លើយតបនៅគ្រប់សមាសភាពនានារបស់ផែនការសកម្មភាពជាតិ។

ការងារអភិវឌ្ឍយុវជននាពេលអនាគត មានវិសាលភាពទូលំទូលាយ ហើយក៏ត្រូវបានដាក់បញ្ចូលទៅក្នុងគោលនយោបាយនានារបស់រាជរដ្ឋាភិបាល ជាពិសេសគឺយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដែលចតុកោណទី១ សំដៅលើការអភិវឌ្ឍធនធានមនុស្ស។ ដើម្បីកំណត់វិសាលភាព ផែនការសកម្មភាពជាតិនេះ នឹងផ្តោតលើបញ្ហាជាក់លាក់សម្រាប់អាទិភាព ដូចមានបង្ហាញក្នុងតារាងខាងក្រោម៖

## តារាងទី ១៖ បញ្ហាជាក់ស្ដែងពាក់ព័ន្ធនឹងយុវជន

**ការអប់រំ និងការបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈ**

- ជំនាញទន់សម្រាប់យុវជននៅក្នុងសាលា និងនៅក្រៅសាលា
- ការអប់រំកម្រិតមូលដ្ឋាន (ផ្នែកអក្ខរកម្ម និងលេខនព្វន្ត) និងបរិស្ថានសិក្សាប្រកបដោយភាពបត់បែន ជាពិសេសសម្រាប់យុវជនក្រៅសាលា
- ការប្រើប្រាស់បច្ចេកវិទ្យា និងបន្ទប់ពិសោធន៍ក្នុងការបង្រៀន និងរៀន
- អក្ខរកម្មឌីជីថល ដែលរួមមានអក្ខរកម្មកុំព្យូទ័រ អក្ខរកម្មបច្ចេកវិទ្យា និងបញ្ហាសីលធម៌
- ការខ្វះ និងគម្លាតជំនាញ និងភាពមិនស៊ីគ្នានៃជំនាញ
- អក្ខរកម្មហិរញ្ញវត្ថុ ជាពិសេសទាក់ទងនឹងបំណុលក្នុងជីវភាពប្រចាំថ្ងៃ និងការប្រើប្រាស់ឥណទានវិសាលភាពគ្របដណ្ដប់នៃការអប់រំបច្ចេកទេសនៅមានកម្រិត។

**សុខភាព និងសុខុមាលភាព**

- ការយល់ដឹង និងសេវាកម្មទាក់ទងនឹងសុខភាពបន្ដពូជនៅមានកម្រិត ជាពិសេសយុវនារី (ឧ. សិទ្ធិ និងសុខភាពផ្លូវភេទ សុខភាពបន្តពូជ ជាពិសេសជំងឺអេដស៍ ជំងឺកាមរោគ មានផ្ទៃពោះមុនវ័យ ការរំលូតកូន និងអំពើហិង្សាផ្លូវភេទ)
- ការកើនឡើងដោយមិនដឹងខ្លួននូវបញ្ហាសុខភាពផ្លូវចិត្តក្នុងចំណោមយុវជន ទាំងក្នុងសាលានិងក្រៅសាលា
- អត្រាខ្ពស់នៃការរងរបួសនិងស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍ ក្នុងចំណោមយុវជន
- ការប្រើប្រាស់គ្រឿងញៀន និងគ្រឿងស្រវឹង ក្នុងចំណោមយុវជនទាំងនៅជនបទនិងទីក្រុង។

**ការងារ និងឱកាស**

- ជំនាញទន់ ជំនាញឥរិយាបថ-សង្គម ដូចជា ការត្រិះរិះពិចារណា ក្រមសីលធម៌ ឥរិយាបថការងារ និងវិជ្ជាជីវៈ ការទំនាក់ទំនង ការធ្វើការងារជាក្រុម និងការដោះស្រាយបញ្ហា
- ការយល់ដឹង និងលទ្ធភាពទទួលបានសេវាប្រឹក្សាយោបល់អាជីព ការងារនិងវិជ្ជាជីវៈ និងព័ត៌មានទីផ្សារការងារ
- ការយល់ដឹងអំពីសិទ្ធិ កាតព្វកិច្ច និងការទទួលខុសត្រូវក្នុងការងារ
- ឱកាស និងការគាំទ្រសម្រាប់ការចុះកម្មសិក្សា និងហាត់ការ
- ការអភិវឌ្ឍសហគ្រិនភាពរបស់យុវជន។

**ការចូលរួមរបស់យុវជន**

- ការចូលរួមរបស់យុវជនក្នុងដំណើរការអភិបាលកិច្ច ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ជំនាញទន់សម្រាប់យុវជនតាមរយៈការងារស្ម័គ្រចិត្តនៅតាមវិស័យនានា និងសកម្មភាពផ្សេងៗ
- ការចូលរួមរបស់យុវជនងាយរងគ្រោះ រួមមានយុវជននៅតាមតំបន់ដាច់ស្រយាល យុវជនជាស្ត្រី យុវជនក្រៅសាលា យុវជនពិការ និងយុវជននៃក្រុមអ្នកស្រឡាញ់ភេទដូចគ្នា(LGBTQI)
- ការរំពឹងទុករបស់យុវជន លើកកម្ពស់ការយល់ដឹងក្នុងចំណោមយុវជន និងការចែករំលែកព័ត៌មានអំពីសេវាកម្ម និងការប្រើប្រាស់សេវា។

# ២. យុទ្ធសាស្ត្រ

## ២.១. យន្តការសម្របសម្រួល

ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល ផែនការសកម្មភាពជាតិ ស្តីពីការអភិវឌ្ឍយុវជនកម្ពុជាឆ្នាំ២០២២-២០២៦ នឹងត្រូវបានអនុវត្តដោយក្រសួង ស្ថាប័ន និងសម្របសម្រួលពិនិត្យតាមដាន និងវាយតម្លៃដោយ អគ្គលេខាធិការដ្ឋាន ក.ជ.យ.។

ផែនការសកម្មភាពជាតិមានគោលដៅ សម្រេចនូវគោលបំណងជាយុទ្ធសាស្ត្រសំខាន់ៗ ដូចមានចែងនៅក្នុងគោលនយោបាយជាតិ ស្តីពីការអភិវឌ្ឍយុវជនកម្ពុជា (២០១១) ដែលនៅតែមានភាពសមស្របជាមួយស្ថានភាពបច្ចុប្បន្នរបស់យុវជន។ គោលបំណងសំខាន់ៗទាំងនោះរួមមាន៖

- ផ្តល់ឱកាសឱ្យយុវជនទទួលបានការអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ បច្ចេកទេស ប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន
- លើកទឹកចិត្ត និងជំរុញឱ្យយុវជនមានគំនិតផ្តួចផ្តើម ច្នៃប្រឌិត នវានុវត្តន៍ និងស្មារតីសហគ្រិនភាព
- លើកកម្ពស់យេនឌ័រប្រកបដោយសមធម៌ និងសមភាពដល់យុវជន ពិសេសផ្តល់ឱកាស និងសិទ្ធិអំណាចដល់ស្ត្រី
- អភិវឌ្ឍយុវជនឱ្យមានកាយសម្បទា សមត្ថភាព គុណធម៌ ចំណេះដឹង ចំណេះធ្វើ សីលធម៌រស់នៅល្អ ចេះរួមរស់ជាមួយគ្នាដោយសន្តិភាព និងសុខដុម ព្រមទាំងមានមនសិការស្នេហាជាតិ ទស្សនជាតិនិយម និងស្មារតីទទួលខុសត្រូវ ស្នេហាប្រជាជន ប្រកបដោយជំនឿលើខ្លួនឯង សេចក្តីថ្លៃថ្នូរ ភាពជាអ្នកដឹកនាំ ថែរក្សាវប្បធម៌ អរិយធម៌ ទំនៀមទម្លាប់ និងប្រពៃណីដ៏ល្អរបស់ជាតិ និងលើកកម្ពស់ការយល់ដឹងទូលំទូលាយពីសង្គម
- ផ្តល់ឱកាសឱ្យយុវជនចែករំលែកទស្សនៈ គំនិត និងចូលរួមធ្វើសេចក្តីសម្រេចនៅក្នុងសហគមន៍ និងការអភិវឌ្ឍប្រទេសជាតិ
- ប្រមូលផ្តុំកម្លាំងគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល សហគមន៍ មាតាបិតា ឬអ្នកអាណាព្យាបាល ដើម្បីអភិវឌ្ឍយុវជនកម្ពុជា។

## ២.២. ក្របខណ្ឌយុទ្ធសាស្ត្រ

អាទិភាពទាំង ៥ ដែលបានលើកឡើង មានការផ្សារភ្ជាប់ទៅនឹងយុទ្ធសាស្ត្រទាំង ១២ នៃគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា ដូចដែលបានបង្ហាញនៅក្នុងតារាងខាងក្រោម៖

## តារាងទី ២៖ អាទិភាព និងយុទ្ធសាស្ត្រ

| អាទិភាព | | យុទ្ធសាស្ត្រ(គោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា (២០១១)) |
|---|---|---|
| ១ | សមត្ថភាពរបស់ស្ថាប័នក្នុងការសម្របសម្រួល ពិនិត្យតាមដាន និងវាយតម្លៃ | យុទ្ធសាស្ត្រទី ១៖ អភិវឌ្ឍក្របខណ្ឌច្បាប់ និងយន្តការ |
| ២ | ការអប់រំ ជំនាញ និងការកសាងសមត្ថភាព | យុទ្ធសាស្ត្រទី២៖ លើកកម្ពស់ការអប់រំ ការបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាព |
| ៣ | សុខភាព សុវត្ថិភាព និង សុខុមាលភាព | យុទ្ធសាស្ត្រទី៣៖ បង្កើនការអប់រំ ការថែទាំ និងការផ្តល់សេវាសុខភាព<br>យុទ្ធសាស្ត្រទី៥៖ ៖ លើកកម្ពស់កិច្ចការពារ សុវត្ថិភាព សន្តិសុខ និងយុត្តិធម៌<br>យុទ្ធសាស្ត្រទី១២៖ ទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀន និងស្តារនីតិសម្បទា |
| ៤ | ការងារ និងសហគ្រិនភាព | យុទ្ធសាស្ត្រទី៤៖ ការបណ្តុះស្មារតីសហគ្រិនភាព និងទីផ្សារការងារ |
| ៥ | ការចូលរួមរបស់យុវជន និងការងារស្ម័គ្រចិត្ត | យុទ្ធសាស្ត្រទី៦៖ បង្កើនការចូលរួមរបស់យុវជន<br>យុទ្ធសាស្ត្រទី៧៖ លើកកម្ពស់ការសម្រាក ការកម្សាន្ត និងកីឡា<br>យុទ្ធសាស្ត្រទី៨៖ លើកកម្ពស់សិល្បៈ និងវប្បធម៌<br>យុទ្ធសាស្ត្រទី៩៖ លើកកម្ពស់ការយល់ដឹងពីបរិស្ថាន កសិកម្ម ទេសចរណ៍ និងធុរកិច្ច<br>យុទ្ធសាស្ត្រទី១០៖ បង្កើនការងារស្ម័គ្រចិត្ត<br>យុទ្ធសាស្ត្រទី១១៖ លើកកម្ពស់សមភាពយេនឌ័រ |

# ៣_ ផែនការសកម្មភាព

## ៣.១_ បរិយាយសង្ខេបអំពីវិសាលភាពនៃផែនការ

ផែនការសកម្មភាពជាតិ ស្ដីពីការអភិវឌ្ឍយុវជនកម្ពុជា មានវិសាលភាពគ្របដណ្ដប់គ្រប់វិស័យនៅក្នុងប្រទេសដែលត្រូវអនុវត្តចាប់ពីឆ្នាំ២០២២ ដល់ឆ្នាំ២០២៦។ ផែនការនេះ បានកំណត់អាទិភាពធំៗចំនួន ៥ និងយុទ្ធសាស្ត្រចំនួន ១២ ព្រមទាំងសកម្មភាពលម្អិត សូចនាករ ចំណុចដៅ ក្របខណ្ឌពេលវេលា ស្ថាប័នអនុវត្ត និងថវិកាគាំទ្រច្បាស់លាស់ ដូចនៅក្នុងតារាងម៉ាទ្រីកខាងក្រោម។

## ៣.២_ តារាងអនុវត្តការងារ

ផ្អែកតាមអាទិភាព និងយុទ្ធសាស្ត្រខាងលើនេះ តារាងផែនការសកម្មភាពត្រូវបានរៀបចំឡើង ដូចខាងក្រោម៖

| អាទិភាព | យុទ្ធសាស្ត្រ | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា (ឆ្នាំ) | | | | | ស្ថាប័ន/អង្គភាព អនុវត្ត | ថវិកា |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ១ | ២ | ៣ | ៤ | ៥ | | |
| ការសម្រប សម្រួល ពិនិត្យ តាមដាន និង វាយតម្លៃស្ថាប័ន | យុទ្ធសាស្ត្រ ១៖ អភិវឌ្ឍក្របខណ្ឌច្បាប់ និងយន្តការ | សម្របសម្រួលភាគីពាក់ព័ន្ធសំខាន់ៗ (ពិសេសអង្គការពាក់ព័ន្ធយុវជន) ទៅលើការអនុវត្តផែនការសកម្មភាពជាតិស្ដីពីការអភិវឌ្ឍយុវជនកម្ពុជា | ចំនួនកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធផ្សេងៗនៃក្រុមការងារបច្ចេកទេសត្រួតពិនិត្យផែនការសកម្មភាពជាតិស្ដីពីការអភិវឌ្ឍយុវជនកម្ពុជា | ៤ដងក្នុងមួយឆ្នាំ (រៀងរាល់ត្រីមាស) | X | X | X | X | X | -អគ្គលេខាធិការដ្ឋាន ក.ជ.យ.<br>-ក្រុមការងារបច្ចេកទេសរបស់ក្រសួងស្ថាប័ន | |
| | | រៀបចំក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តផែនការ | ក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តផែនការសកម្មភាពជាតិស្ដី | ក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃត្រូវបានរៀបចំ និងអនុម័ត | | X | X | | | -អគ្គលេខាធិការដ្ឋាន ក.ជ.យ. | |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | សកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា ជាទៀងទាត់ | ពីការអភិវឌ្ឍយុវជនកម្ពុជាត្រូវបានរៀបចំ និងអនុម័ត | | | | | | | -ក្រុមការងារបច្ចេកទេសរបស់ក្រសួង ស្ថាប័ន រាជធានី ខេត្ត | |
| | | រៀបចំប្រព័ន្ធព័ត៌មានគ្រប់គ្រងទិន្នន័យយុវជន | ប្រព័ន្ធព័ត៌មានគ្រប់គ្រងទិន្នន័យយុវជនត្រូវបានរៀបចំ | ប្រព័ន្ធព័ត៌មានគ្រប់គ្រងទិន្នន័យយុវជន ត្រូវបានរៀបចំ និងអនុម័តដាក់ឱ្យប្រើប្រាស់ | | | X | X | X | -អគ្គលេខាធិការដ្ឋាន ក.ជ.យ.<br>-ក្រុមការងារបច្ចេកទេសរបស់ក្រសួង ស្ថាប័ន រាជធានី ខេត្ត | |
| | | ផ្សព្វផ្សាយគោលនយោបាយជាតិ និងផែនការសកម្មភាពជាតិ ស្តីពីការអភិវឌ្ឍយុវជនកម្ពុជា (ពិសេស យុវជនងាយរងគ្រោះ) | គោលនយោបាយជាតិ និងផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជាត្រូវបានផ្សព្វផ្សាយ | មួយដងក្នុងមួយឆ្នាំ | X | X | X | X | X | អគ្គលេខាធិការដ្ឋាន ក.ជ.យ. | |
| | | ឈ្វេងយល់ឱ្យកាន់តែច្បាស់ពីស្ថានភាពយុវជន និងយុវជនងាយរងគ្រោះ | លទ្ធផលស្រាវជ្រាវស្តីពីស្ថានភាពយុវជនកម្ពុជា | លទ្ធផលស្រាវជ្រាវចំនួនមួយ | | | X | | | អគ្គលេខាធិការដ្ឋាន ក.ជ.យ. | |
| | | ធ្វើបច្ចុប្បន្នកម្មសន្ទស្សន៍អភិវឌ្ឍន៍យុវជនកម្ពុជា | សន្ទស្សន៍អភិវឌ្ឍន៍យុវជនកម្ពុជាត្រូវបានធ្វើបច្ចុប្បន្នកម្ម | ប្រាំឆ្នាំម្តង | | | | | X | -អគ្គលេខាធិការដ្ឋាន ក.ជ.យ.<br>-ក្រុមការងារបច្ចេកទេសរបស់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ដៃគូអភិវឌ្ឍន៍ | |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | រៀបចំរបាយការណ៍ជាតិស្តីពីការអភិវឌ្ឍយុវជន | របាយការណ៍ជាតិស្តីពីការអភិវឌ្ឍយុវជនត្រូវបានរៀបចំ និងបោះពុម្ពផ្សាយ | រៀងរាល់ឆ្នាំ | X | X | X | X | X | -អគ្គលេខាធិការដ្ឋាន ក.ជ.យ.<br>-ក្រុមការងារបច្ចេកទេសរបស់ក្រសួងស្ថាប័ន រាជធានី ខេត្ត | |
| | | ធ្វើនីត្យានុកូលកម្មក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួង ស្ថាប័ន និងរាជធានី ខេត្ត | ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួង ស្ថាប័ន និងរាជធានី ខេត្ត ត្រូវបានធ្វើនីត្យានុកូលកម្ម | គ្រប់ក្រសួងស្ថាប័ន និងរាជធានី ខេត្ត | | X | X | | | -អគ្គលេខាធិការដ្ឋាន ក.ជ.យ.<br>-ក្រុមការងារបច្ចេកទេសរបស់ក្រសួងស្ថាប័ន រាជធានី ខេត្ត | |
| | | ផ្សព្វផ្សាយយុវជនឱ្យយល់ដឹងលិខិតបទដ្ឋានគតិយុត្តិ | ចំនួនយុវជនយល់ដឹងច្រើន | ៥០នាក់ ២ដង/១ឆ្នាំ | X | X | X | X | X | -ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | |
| | | ការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទក្រសួងដោយរំលេចតួនាទីភារកិច្ចយុវជនក្នុងការចូលរួមអភិវឌ្ឍន៍វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ចំនួនយុវជនចូលរួមសិក្ខាសាលាពិគ្រោះយោបល់ | ២០០នាក់ | | | X | X | X | -ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | |
| ការអប់រំ ការបណ្តុះបណ្តាល និងការកសាងសមត្ថភាព | យុទ្ធសាស្ត្រទី២៖ លើកកម្ពស់ការអប់រំ ការបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាព | លើកកម្ពស់ការទទួលបានសេវាអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈរបស់យុវជន ជាពិសេសយុវជនដែលពុំសូវមាន | ចំនួនយុវជនដែលបានបញ្ចប់ការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ | ៤០០០០ នាក់ក្នុងមួយឆ្នាំ និងកំណើន ១០% ជារៀងរាល់ឆ្នាំ (យ៉ាងហោចណាស់ ២៥% ជាស្ត្រី) | X | X | X | X | X | -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>-ក្រសួងទេសចរណ៍<br>-ដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល | |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| សម្រាប់យុវជនងាយរងគ្រោះ | | ឱកាស និងយុវជនដែលងាយរងគ្រោះ ក្នុងនោះជនមានពិការភាព និងស្ត្រី | | | | | | | | | |
| | | រៀបចំកម្មវិធីបណ្តុះបណ្តាលជំនាញទន់ស្តង់ដា និងសម្ភារបណ្តុះបណ្តាលសម្រាប់យុវជននៅក្នុងសាលា (រួមមាន ការត្រិះរិះពិចារណា ក្រមសីលធម៌ និង(ឥរិយាបថការងារ និងវិជ្ជាជីវៈ ការទំនាក់ទំនង ការធ្វើការងារជាក្រុម និងការដោះស្រាយបញ្ហា) និងនិងការយោគយល់គ្នារវាងសាសនា និងវប្បធម៌ផ្សេងៗគ្នា និងវិជ្ជាជីវៈការងារ) | កម្មវិធីបណ្តុះបណ្តាលជំនាញទន់ស្តង់ដា ត្រូវបានអនុម័ត | កម្មវិធីបណ្តុះបណ្តាលជំនាញទន់ស្តង់ដា ត្រូវបានអនុម័ត | | | X | | | -ក្រសួងអប់រំ យុវជន និងកីឡា<br>-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>-ដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល | |
| | | លើកកម្ពស់ការយល់ដឹងរបស់យុវជនអំពីការគ្រប់គ្រងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ | ចំនួនយុវជនទទួលបានការបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ | ៥០០នាក់ក្នុងមួយឆ្នាំ (យ៉ាងហោចណាស់ ៤០% ជាស្ត្រី) | x | x | X | x | x | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | |
| | | បណ្តុះបណ្តាលជំនាញទន់តាមការកំណត់ក្នុងស្តង់ដាបណ្តុះបណ្តាលផ្អែកលើ | ចំនួនយុវជនទទួលបានការបណ្តុះបណ្តាលជំនាញទន់តាមការកំណត់ក្នុងស្តង់ដា | ៣០០នាក់ក្នុងមួយឆ្នាំ (យ៉ាងហោចណាស់ ៤០% ជាស្ត្រី) | x | x | X | x | x | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | សមត្ថភាព និងសម្រាប់ឈានចូលទីផ្សារការងារ | បណ្តុះបណ្តាលផ្អែកលើសមត្ថភាព និងសម្រាប់ឈានចូលទីផ្សារការងារ | | | | | | | | |
| | | បណ្តុះបណ្តាលជំនាញទន់ និងសម្ភារបណ្តុះបណ្តាលសម្រាប់យុវជននៅក្រៅសាលា (រួមមាន ការត្រិះរិះពិចារណា ក្រមសីលធម៌ និង (ឥរិយាបថការងារ និងវិជ្ជាជីវៈ ការទំនាក់ទំនង ការធ្វើការងារជាក្រុម និង ការដោះស្រាយបញ្ហា) | ចំនួនយុវជនទទួលបានការបណ្តុះបណ្តាលជំនាញទន់ តាមការកំណត់ក្នុងស្តង់ដាបណ្តុះបណ្តាលផ្អែកលើសមត្ថភាព និងសម្រាប់ឈានចូលទីផ្សារការងារ | ៣០០នាក់ក្នុងឆ្នាំ (យ៉ាងហោចណាស់ ៤០% ជាស្ត្រី) | | | X | | | -ក្រសួងអប់រំ យុវជន និងកីឡា<br>-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>-ដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល | |
| | | ពង្រីកវិសាលភាព និងបង្កើនការចុះឈ្មោះចូលរៀនរបស់យុវជនក្នុងកម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ិនធឺណិត (ប៊ីប/BEEP) ដល់យុវជនបោះបង់ការសិក្សាក្នុងកម្រិតមធ្យមសិក្សាបឋមភូមិ | ចំនួនយុវជនបានបញ្ចប់ការសិក្សាតាមកម្មវិធីប៊ីប/ BEEP | ២៥០នាក់ក្នុងមួយឆ្នាំ (យ៉ាងហោចណាស់ ៤០% ជាស្ត្រី) | X | X | X | X | X | -ក្រសួងអប់រំ យុវជន និងកីឡា<br>-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>-ដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល | |
| | | អនុវត្តកម្មវិធីពង្រឹងសមត្ថភាពអក្ខរកម្មឌីជីថលសម្រាប់យុវជន | ចំនួនយុវជន(ការប្រើប្រាស់) ចូលរួមកម្មវិធីអក្ខរកម្មឌីជីថល | ១៥០០នាក់ក្នុងមួយឆ្នាំ (៣០% ជាស្ត្រី) | X | X | X | X | X | -ក្រសួងអប់រំ យុវជន និងកីឡា | |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | -ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>-ដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល | |
| | | ពង្រីកការបណ្តុះបណ្តាលជំនាញឌីជីថល និងបច្ចេកវិទ្យាព័ត៌មានតាមការកំណត់ក្នុងស្តង់ដាបណ្តុះបណ្តាលផ្អែកលើសមត្ថភាព | ចំនួនយុវជនទទួលបានការបណ្តុះបណ្តាលកើនឡើងរៀងរាល់ឆ្នាំ | ១០០នាក់ក្នុងមួយឆ្នាំ (៣០% ជាស្ត្រី) | X | X | X | X | X | -ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>-ក្រសួងអប់រំ យុវជន និងកីឡា | |
| | | បង្កើនការយល់ដឹងអំពីទេសន្តប្រវេសន៍ការងារប្រកបដោយសុវត្ថិភាពក្នុងចំណោមយុវជន | ចំនួនយុវជនយល់ដឹង អំពីទេសន្តប្រវេសន៍ការងារប្រកដោយសុវត្ថិភាព | ៥០នាក់ក្នុងមួយឆ្នាំ (យ៉ាងហោចណាស់ ៤០% ជាស្ត្រី) | X | X | X | X | X | -ក្រសួងអប់រំ យុវជន និងកីឡា<br>-ក្រសួងមហាផ្ទៃ (អគ្គលេខាធិការដ្ឋាន គជបជ-NCCT)<br>-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>-ដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល | |
